ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៧៩៧ / ១៧.៨.២០១២

សាលដីកា

លេខ:១០៥ ក្រ.III.ស/២៦.១២.២០១២

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៧៩៧ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ ឆាង ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ មុខរបរៈសន្តិសុខឯកជនក្រុមហ៊ុន ស៊ី អេស អិម ទីលំនៅកំណើតភូមិច្រេស [redacted] រាជធានីភ្នំពេញ ទីលំនៅមុនឃាត់ខ្លួន ផ្ទះលេខ៧២ ផ្លូវលំ ក្រុម១ ភូមិច្រេស សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន ឃាត់ខ្លួនថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ឃុំខ្លួនថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២។

មេធាវីការពារជនជាប់ចោទលោក [redacted] ម៉ាច។

ជាប់ចោទពីបទ: លួច (មានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា) ប្រព្រឹត្តនៅ ភូមិសំរោងទាវ សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ បទល្មើស ព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភក្តិ ភេទប្រុស អាយុ២២ឆ្នាំ មុខរបរៈជាងភ្លើង ទីលំនៅសព្វថ្ងៃ ភូមិក្រាំងធ្នង់ សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] គង្គា ភេទប្រុស អាយុ២៣ឆ្នាំ មុខរបរៈយោធា ទីលំនៅសព្វថ្ងៃ ភូមិក្រាំងអង្គ្រង សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**<u>៦ដំណើររឿងមានដូចតទៅ ៖</u>**

កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ វេលាម៉ោង២៣ និង៣០នាទី យប់ នៅចំណុច ភូមិសំរោងទាវ សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានករណីស្ទាក់វាយយកកង់ និងស្បែកជើងរបស់ ជនរងគ្រោះឈ្មោះ [redacted] គង្គា និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភក្តិ ដែលបង្កឡើងដោយជនជាប់ចោទ ឈ្មោះ ឆាង និងគូកនមានឈ្មោះ [redacted] ប៊ុនធឿន និងឈ្មោះ [redacted] សារី។ តាមចម្លើយជនរងគ្រោះថា ក្រោយពេល កើតហេតុ ជនត្រូវចោទបានយកកង់របស់ខ្លួនទៅបោះចោលនៅស្រះទឹកខាងកើតភូមិ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ.១ «ង» ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១- ប្តូរបទបញ្ញត្តិនៃការចោទប្រកាន់ លើជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] សារី ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ពីបទ ប្លន់ តាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកបទ លួច (មានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហឹង្សា) តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] សារី ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់៣ (បី) ឆ្នាំ ពីបទ លួច (មានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា) ប្រព្រឹត្តនៅ ភូមិសំរោងទាវ សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ តាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣- បង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនឈ្មោះ [redacted] សារី ដែលមានអត្តសញ្ញាណខាងលើ ដោយអនុវត្តតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន មេធាវីការពារជនជាប់ចោទ ជនរងគ្រោះឈ្មោះ [redacted] គង្គា, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារី និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភក្តិ, ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ប៊ុនធឿន ជាជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៤ ក្រ «ង» ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។៚

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]គង្គា និងឈ្មោះ [redacted]ភក្តី ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted]ប៊ុនធឿន ឆ្លើយថា នៅថ្ងៃកើតហេតុ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ ខ្លួនទៅលេងបុណ្យ, លុះចន្លោះពីម៉ោង១០ និង៣០នាទី ទៅម៉ោង១១យប់ ខ្លួនត្រឡប់ទៅផ្ទះវិញ ក៏ឃើញគេទាស់ប្រតាយគ្នា នៅកាច់ជ្រុងវិហារចិន គឺម្ខាងជាមិត្តភក្រ្តខ្លួន មានគ្នា១០នាក់ វាយគ្នាជាមួយពួកមួយផ្សេងទៀត, ពេលនោះខ្លួនពុំបានចូលរួមទេ តែខ្លួនបានឃើញអ្នកភូមិខាងជើងអូសយកកង់ចេញពីកន្លែងកើតហេតុ ហើយខ្លួនស្រូតទៅផ្ទះ, លុះព្រឹកឡើងទើបដឹងថា ពួកម៉ាកខ្លួនមានរបួស, មូលហេតុខ្លួនចេញពីភូមិក្រោយពេលកើតហេតុព្រោះខ្លួនទីទ័លក្រ ខ្លួនបានទៅរកស៊ីនៅខេត្តកំពង់ឆ្នាំងអស់រយៈពេល៤ឆ្នាំ មិនដែលត្រឡប់មកស្រុកទេ ហើយក៏គ្មានទំនាក់ទំនងដែរ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] ចាន់ថន, ឈ្មោះ [redacted] ភឺន និងឈ្មោះ [redacted] ញ៉ាញ់ បានឆ្លើយនៅនគរបាល និងនៅសាលាដំបូងរាជធានីភ្នំពេញ។

ឈ្មោះ [redacted]ប៊ុនធឿន ឆ្លើយថា ខ្លួនអត់ស្គាល់សាក្សីទាំងបីនាក់នេះទេ សំណូមពរ សូមជួយរកយុត្តិធម៌ឲ្យខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់របាយការណ៍ ក្រោយពីស្តាប់ការសួរដេញដោលជនជាប់ចោទ ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី, ក្នុងរឿងនេះ តំណាងមហាអយ្យការនៅតែមានវិមតិសង្ស័យទៅលើឈ្មោះ ឆាង បើតាមចម្លើយសាក្សីទាំងនេះបានឆ្លើយថា អ្នកប្រព្រឹត្តមានឈ្មោះ ឆាង តែមិនបានបញ្ជាក់ពីភិនភាគថាយ៉ាងម៉េចទេ បើជនជាប់ចោទបានប្រព្រឹត្តតំណាងមហាអយ្យការយល់ឃើញថា ជនជាប់ចោទនឹងសារភាព តែពេលនេះជនជាប់ចោទបានឆ្លើយថា មិនបានប្រព្រឹត្តទេ ហើយក្នុងរឿងនេះសាលាដំបូងបានសម្រេចផ្តន្ទាទោសពីបទ លួចដោយហិង្សា តែក្នុងរឿងនេះមានការវាយដៃនិងដៃ បើគិតមើលពីព្យសនកម្មឃើញថាមានលក្ខណៈតិចតួច បើសិនក្រុមប្រឹក្សាពិនិត្យឃើញថា ជនជាប់ចោទពិតជាឈ្មោះ ឆាង នេះពិតមែន តំណាងមហាអយ្យការសុំក្រុមប្រឹក្សាពិចារណាលើមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ខ្លួនសុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់លោកតំណាងមហាអយ្យការ, តាមចម្លើយកូនក្តីខ្លួនឆ្លើយ

ថា គាត់ពុំបានប្រព្រឹត្តទេ ហើយបើតាមអង្គហេតុ គឺមានព្យសនកម្មតិចតួចបំផុត សុំក្រុមប្រឹក្សាជំនុំជម្រះ មេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយអនុគ្រោះ។

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

**សភាព្រហ្មទណ្ឌ**

**យល់ឃើញថា:**

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ប៊ុនធឿន ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទថា នៅថ្ងៃកើតហេតុ ខ្លួនទៅលេងបុណ្យ, លុះចន្លោះពីម៉ោង ១០ និង ៣០នាទី ទៅម៉ោង១១យប់ នៃថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ ខ្លួនត្រឡប់ទៅផ្ទះវិញ ក៏ឃើញគេទាស់ប្រតាយគ្នានៅកាច់ជ្រុងវិហារចិន គឺម្ខាងជាមិត្តភក្តិខ្លួន មានគ្នា១០នាក់ វាយគ្នាជាមួយពួកមួយផ្សេងទៀត, ពេលនោះខ្លួនពុំបានចូលរួមទេ តែខ្លួនបានឃើញអ្នកភូមិខាងជើងអូសយកកង់ចេញពីកន្លែងកើតហេតុ ហើយខ្លួនស្រូតទៅផ្ទះ, លុះព្រឹកឡើងទើបដឹងថា ពួកម៉ាកខ្លួនមានរបួស ខ្លួនក៏ទៅរកស៊ីនៅខេត្តកំពង់ឆ្នាំង អស់រយៈពេល៤ឆ្នាំ មិនដែលត្រឡប់មកស្រុកទេ ហើយក៏គ្មានទំនាក់ទំនងដែរ។

៣. តាមចម្លើយជនជាប់ចោទ និងសាក្សី បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ ឆាង និងឈ្មោះ [redacted] សារី ពិតជាបានវាយជនរងគ្រោះនៅពេលនោះមែន ហើយតាមចម្លើយសាក្សីឈ្មោះ [redacted] ចាន់ថន បានបញ្ជាក់នៅចម្លើយរបស់ខ្លួនថា ពេលខ្លួនចេញពីកន្លែងនោះ ខ្លួនឮសម្លេងស្រែកថា ពួកអាក្មេង ក្រាំងអង្គ្រង ទៅយកកង់ពួកហ្អែងនៅស្រះទឹកខាងកើតភូមិទៅ។

៤. មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ លួចដោយហឹង្សា ប្រព្រឹត្តនៅ ភូមិសំរោងទាវ សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ បទល្មើស ព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនជាប់ចោទទើបប្រព្រឹត្តល្មើសជាលើកទី១ ហើយប្រព្រឹត្តដោយមានទំនាស់ទាស់ទែងវាយតប់គ្នាមិនមានចេតនាយកទ្រព្យ គឺកង់របស់ជនរងគ្រោះទៅធ្វើជាកម្មសិទ្ធិ ឬ ក៏យកទៅលក់-បញ្ចាំជាប្រយោជន៍ផ្ទាល់ខ្លួនទេ គឺគ្រាន់តែយកទៅបោះចោលទៅក្នុងទឹកស្រះប៉ុណ្ណោះ ហើយស្រែកប្រាប់ជនរងគ្រោះឲ្យទៅយកកង់នៅក្នុងទឹកស្រះខាងកើតភូមិ ហើយជនរងគ្រោះបានទទួលយកកង់ទាំងពីរគ្រឿងនោះវិញអស់ហើយ ប៉ុន្តែ ចំពោះ

ស្បែកជើងរបស់ជនរងគ្រោះរកមិនឃើញ គឺដោយជនជាប់ចោទយក។

ដូច្នេះ គួរពិចារណាតាមមាត្រា១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ លើការអនុវត្តទោសរបស់ជនជាប់ចោទ

៥. សាលក្រមព្រហ្មទណ្ឌលេខ ៤៤ ក្រ «ង» ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំនុចទី២ ស្តីពីការអនុវត្តទោសនៃជនជាប់ចោទឈ្មោះ [redacted]ប៊ុនធឿន គួរកែប្រែដូចយល់ឃើញខាងលើ, ក្រៅពីនេះគួររក្សាទុកនៅដដែល។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២ របស់ឈ្មោះ [redacted]ប៊ុនធឿន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៤ ក្រ «ង» ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការលើកលែងតែការអនុវត្តទណ្ឌកម្មនៃជនជាប់ចោទ ត្រូវបែងចែកជាៈ បង្គាប់ឲ្យជនជាប់ចោទ អនុវត្តទោសនៅក្នុងពន្ធនាគារ កំណត់រយៈពេល ០១ (មួយ) ឆ្នាំ គិតពីថ្ងៃចាប់ឃាត់ខ្លួន ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ទោសសល់សម្រេចព្យួរធម្មតា តាមមាត្រា ១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ, ក្រៅពីនេះទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ, បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃនេះទៅ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបាន សម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។ ៕**

ក្រឡាបញ្ជី
ហត្ថលេខា: [redacted]

ចៅក្រមប្រឹក្សា
ហត្ថលេខា: [redacted] [redacted]

ប្រធានក្រុមប្រឹក្សា
ហត្ថលេខា: [redacted]

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ.២០១៤
ក្រឡាបញ្ជី
[redacted]